# សំរាម

*ការពិនិត្យឡើងវិញនូវទីតាំងចោលសំរាមចំនួន ១៤៧ ចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៦ ក្នុងរាជធានីភ្នំពេញ*

*F និង F*

# #31

*ខែធ្នូ ឆ្នាំ២០១៦*

*ការពិត និងតួលេខ*

គឺជាការបោះពុម្ពផ្សាយពីបញ្ហាក្នុងតំបន់ទីក្រុងដោយសមាគមធាងត្នោត (STT)

សមាគមធាងត្នោត

Sahmakum Teang Tnaut. a Cambodian Urban NGO

ក្រុមការងារស្រាវជ្រាវ៖ កញ្ញា ដានីញ៉ែល ហ្គីល, លោកស្រី គាំ ចាន់រស្មី, លោក ច្រឹក សុភា, លោក ស៊ិន សុក្រឹត្យ, លោកស្រី ភឿន ច័ន្ទអារុណ, លោក យឿន ឌីនិត, កញ្ញា សារ៉ា រ៉ូស ជេនស៊ិន

ការបោះពុម្ពផ្សាយនេះឧបត្ថម្ភដោយ៖ DIAKONIA, Heinrich Böll Foundation and MISEREOR

ការប្រមូលសំរាមដែលមានប្រសិទ្ធភាពនិងប្រសិទ្ធផលគឺជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់មួយនៅរាជធានីភ្នំពេញអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ប៉ុន្តែអាចនឹងមានស្ថានភាពកាន់តែអាក្រក់ដោយសារតែមានការពង្រីកទីក្រុងជាបន្តបន្ទាប់ ហើយកំណើនប្រជាជនត្រូវបានរំពឹងថានឹងកើនឡើងដល់បីលាននាក់មុនឆ្នាំ២០១៧[1]។ ការប្រមូលសំរាមដែលមិនមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ បង្កឱ្យមានសត្វចង្រៃនិងបណ្ដាលឱ្យជំងឺរីករាលដាលឡើង។ វាក៏កាត់បន្ថយតម្លៃនៃអចលនទ្រព្យនិងជះឥទ្ធិពលដល់វិស័យទេសចរណ៍ផងដែរ[2]។ ក្រុមហ៊ុនស៊ិនទ្រីដែលជាក្រុមហ៊ុនបម្រើសេវាកម្មប្រមូលសំរាមឯកជន គឺជាក្រុមហ៊ុនផ្ដាច់មុខនៅរាជធានីភ្នំពេញចាប់តាំងពីបានចុះកិច្ចសន្យាដោយរដ្ឋាភិបាលនៅឆ្នាំ២០០២[3] ប៉ុន្តែប្រជាពលរដ្ឋមានការសង្ស័យថាតើក្រុមហ៊ុននោះអាចធ្វើឱ្យ (និងថែរក្សា) ទីក្រុងស្អាតមានអនាម័យដែរឬទេ៖ "ការរំពឹងទុកជាសាធារណៈ ... បានប្រសើរឡើងនិងបង្កើតឡើងលើសពីគំរូបច្ចុប្បន្នអាចផ្ដល់ឱ្យឬយ៉ាងណា"[4]។ ប្រជាពលរដ្ឋមិនបានពេញចិត្តនឹងការងាររបស់ក្រុមហ៊ុនស៊ិនទ្រីឡើយ ចាប់តាំងពីពេលចាប់ផ្ដើម ប៉ុន្តែក្រុមហ៊ុនស៊ិនទ្រីបានអះអាងថាប្រជាពលរដ្ឋ "មិនត្រូវស្ដីបន្ទោសចំពោះសំរាមតាមដងផ្លូវដែលនៅរាយប៉ាយក្នុងទីក្រុងឡើយ" និងថារដ្ឋាភិបាលកំពុងតែប្រើប្រាស់ខ្លួនជារបាំងនៃចំណុចខុសឆ្គងរបស់ខ្លួន[5]។ ទោះជាយ៉ាងណាក៏ដោយ កិច្ចសន្យារបស់ក្រុមហ៊ុនស៊ិនទ្រីត្រូវបានពិនិត្យឡើងវិញ ហើយបន្តទៀតនៅខែឧសភា ឆ្នាំ២០១៦ជាថ្មី[6]។ ក្រុមហ៊ុនឯកជនមានគោលដៅមួយក្នុងការសម្រេចបាននូវ "ប្រព័ន្ធប្រមូលសំរាមដែលមាននិរន្តរភាព"នៅឆ្នាំ២០១៥[7] ប៉ុន្តែនៅពេលរបាយការណ៍នេះត្រូវបានបង្ហាញឡើង វាមានភាពច្បាស់លាស់ថា គោលដៅនេះមិនទាន់បានបំពេញនោះទេ។

---

[1] Meng, S. (2016). Phnom Penh’s burgeoning population could tip almost 3 million. The Phnom Penh Post. [online] Available at: http://www.phnompenhpost.com/post-property/phnom-penhs-burgeoning-population-could-tip-almost-3-million

[2] Wood, R. (2004). Phnom Penh struggles with its garbage. The Phnom Penh Post. [online] Available at: http://www.phnompenhpost.com/national/phnom-penh-struggles-its-garbage

[3] Meta, K. (2016). Cintri rewarded with contract extensions. The Phnom Penh Post. [online] Available at: http://www.phnompenhpost.com/national/cintri-rewarded-contract-extensions

[4] Morales, J. (2015). A New Way for Waste in Phnom Penh? - The Asia Foundation. [online] The Asia Foundation. Available at: http://asiafoundation.org/2015/04/15/a-new-way-for-waste-in-phnom-penh/

[5] Sovuthy, K. (2015). Phnom Penh’s Trash Problem Bigger Than Cintri, Company Says. The Cambodia Daily. [online] Available at: https://www.cambodiadaily.com/archives/phnom-penhs-trash-problem-bigger-than-cintri-company-78180/

[6] Meta, K. (2016). Cintri rewarded with contract extensions. The Phnom Penh Post. [online] Available at: http://www.phnompenhpost.com/national/cintri-rewarded-contract-extensions

[7] Wood, R. (2004). Phnom Penh struggles with its garbage. The Phnom Penh Post. [online] Available at: http://www.phnompenhpost.com/national/phnom-penh-struggles-its-garbage

ផ្លូវ ១៤



ប្រភព៖សមាគមធាងត្នោតឆ្នាំ២០១៤

ផ្លូវ ៨៦កា



ប្រភព៖ សមាគមធាងត្នោតឆ្នាំ២០១៦

ផ្លូវ ៣៥០



ប្រភព៖ សមាគមធាងត្នោតឆ្នាំ២០១៦

## វិធីសាស្ត្រ

របាយការណ៍នេះបានប្រើប្រាស់បណ្តុំនៃទិន្នន័យដែលបានប្រមូលកាលពីឆ្នាំ២០១៤នៅពេលករណីចំនួន ៣២១នៃសំរាមដែលមិនបានប្រមូលត្រូវបានរាយការណ៍ទៅកម្មវធីសំឡេងទីក្រុង[8]។ ដោយសារតែសមាគមធាងត្នោតមិនមានធនធានក្នុងការពិនិត្យកន្លែងចោលសំរាមទាំង៣២១ម្តងទៀតបាន រូបមន្តខាងក្រោមត្រូវបានប្រើប្រាស់ដើម្បីស្វែងរកទំហំសំណាកគំរូចេញពីកន្លែងទាំង ៣២១ នោះ៖

$$\text{ទំហំសំណាកគំរូ} = \frac{\frac{z^2 \times p(1-p)}{e^2}}{1 + \left(\frac{z^2 \times p(1-p)}{e^2 N}\right)}$$

ទំហំចំនួនប្រជាជន = N, កម្រិតខុស = e, ពិន្ទុ z = z

e គឺជាភាគរយដែលត្រូវបំប្លែងទៅជាលេខទសភាគ (ឧទាហរណ៍ 3% = 0.03) ។

ពិន្ទុ z គឺជាលេខនៃគម្លាតស្តង់ដារដែលសមាមាត្រផ្តល់ឱ្យគឺនៅឆ្ងាយពីមធ្យម។

ដោយមានកម្រិតជឿជាក់ចំនួន ៩០% កម្រិតខុស ៥% និង ពិន្ទុ z ចំនួន ១.៦៥ ទំហំសំណាកគំរូសំខាន់ចំពោះស្ថិតិនៃកន្លែងចំនួន ១៤៧ ត្រូវបានគណនាឡើង។ បន្ទាប់មក ឧបករណ៍ជ្រើសរើសលេខដោយចៃដន្យត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសសំណុំទិន្នន័យដោយចៃដន្យ ហើយសំណាកគំរូនៃកន្លែងចំនួន ១៤៧ ត្រូវបានបង្កើតឡើង។ ក្រុមស្រាវជ្រាវនេះបានចុះទៅន្លែងនីមួយៗក្នុងចំណោម១៤៧កន្លែង។ កន្លែងបន្ថែមយកចេញពីបណ្តុំទិន្នន័យដែលបានជ្រើសរើសដៃចៃដន្យ ត្រូវបានយកមកជំនួសកន្លែងចំនួន ៨ ដែលក្រុមការងារមិនអាចទៅដល់។

[8] Urban Voice is a platform that allows Phnom Penh citizens to define problems and seeks solutions to urban issues. The initial 321 trash sites were identified by local people who uploaded information to the Urban Voice webpage.

## ទិដ្ឋភាពទូទៅ

របាយការណ៍ខាងក្រោមនេះបានបង្ហាញពីទីតាំងចំនួន១៤៧ជុំវិញរាជធានីភ្នំពេញដែលត្រូវបានកំណត់ថាជាតំបន់ដែលមានបញ្ហាសំរាមនៅឆ្នាំ២០១៤។ កន្លែងនីមួយៗត្រូវបានចាត់ចូលជាតំបន់ "ល្អប្រសើរជាងមុន" "ដូចពីមុន" ឬ "កាន់តែអាក្រក់ជាងមុន"៖

| | |
|---|---|
| **ល្អប្រសើរជាងមុន** | សំរាមមិនសូវជាបញ្ហានៅឆ្នាំ២០១៦ ដែលវាធ្លាប់មានស្ថានភាពអាក្រក់នៅឆ្នាំ២០១៤។ នេះមានន័យថា ឥឡូវនេះវាត្រូវបានរៀបចំឡើងនៅកន្លែងដែលកាលពីមុនមិនមានការរៀបចំអ្វីឡើយ ឬដែលថាបច្ចុប្បន្នក្រុមហ៊ុនស៊ិនទ្រីបានប្រមូលសំរាមទៀងទាត់ដែលមិនបណ្តាលឱ្យមានគំនរសំរាមទៀតទេ។ |
| **ដូចពីមុន** | ស្ថានភាពសំរាមនៅឆ្នាំ២០១៦ មិនបានល្អប្រសើរឡើង ឬអាក្រក់ជាងមុនជារួមនោះទេចាប់តាំងពីឆ្នាំ២០១៤មក។ ក្នុងករណីខ្លះ កន្លែងនេះនឹងត្រូវបានចែកជាប្រភេទជា "ដូចពីមុន" នៅពេលទិដ្ឋភាពមួយមានលក្ខណៈប្រសើរឡើង (ឧទាហរណ៍ ឥឡូវនេះ សំរាមត្រូវបានរៀបចំឡើង) ប៉ុន្តែកន្លែងផ្សេងទៀតកាន់តែមានស្ថានភាពអាក្រក់ឡើង (ឧទាហរណ៍ ទឹកកខ្វក់ដោយសារតែគំនរសំរាម)។ កន្លែងក្នុងប្រភេទ "ដូចពីមុន" នឹងមានភាពខុសប្លែកគ្នានៅកម្រិតធ្ងន់ធ្ងរ។ ឧទាហរណ៍ តំបន់ដែលមានស្ថានភាពអាក្រក់នៅឆ្នាំ២០១៤ ហើយនៅតែអាក្រក់នៅឆ្នាំ២០១៦ឬកន្លែងមួយដែលមានស្ថានភាពធម្មតានៅឆ្នាំ២០១៤ ប៉ុន្តែមិនមានលក្ខណៈល្អប្រសើរ ឬកាន់តែអាក្រក់ឡើយចាប់តាំងពីពេលនោះ។ |
| **កាន់តែអាក្រក់ជាងមុន** | ចាប់តាំងពីឆ្នាំ២០១៤ បញ្ហាសំរាមកាន់តែមានស្ថានភាពអាក្រក់ឡើង។ នេះប្រហែលជាបណ្តាលមកពីក្រុមហ៊ុនស៊ិនទ្រីមិនបានប្រមូលឬប្រមូលតាមធម្មតាឬដោយសារតែសំរាមមិនត្រូវបានរៀបចំឱ្យបានត្រឹមត្រូវនិងបន្តគរឡើង។ |

**ពាក្យគន្លឹះ៖**

| | |
|---|---|
| C= ការប្រមូលសំរាមរបស់ក្រុមហ៊ុនស៊ិនទ្រី | Cor.= កែងនឹង |
| O= សំរាមដែលបានរៀបចំរួច | Hwy.= ផ្លូវហាយវេ |
| D= ជិតតំបន់អភិវឌ្ឍន៍ | St.= ផ្លូវ |
| S= ជិតប្រព័ន្ធលូទឹកសម្អុយ | Blvd.= មហាវិថី |
| | Dist.= ស្រុក/ខណ្ឌ |

សំរាមដែលបានរៀបចំរួចត្រូវដាក់ចូលទៅក្នុងថង់ប្លាស្ទិក ឬធុងសំរាមរង់ចាំក្រុមហ៊ុនស៊ិនទ្រីមកប្រមូល។ ក្រុមហ៊ុនស៊ិនទ្រីនឹងប្រមូលតែសំរាមណាដែលបានរៀបចំត្រឹមត្រូវដែលជារឿយៗទុកចោលសំរាមណាដែលមិនបានរៀបចំ ឬមិនសូវទៅប្រមូលសំរាម។ កន្លែងនៅជិតប្រព័ន្ធលូទឹកសម្អុយអាចបង្កើតបញ្ហាបន្ថែម ប្រសិនបើសំរាមត្រូវបានបោះចូលទៅក្នុងប្រព័ន្ធលូនោះទេ។ នេះអាចបង្កើតបញ្ហាជាច្រើន

ជាមួយនឹងការជះឥទ្ធិពលដល់កម្រិតអនាម័យ ទឹកជំនន់ ជាពិសេសក្នុងអំឡុងរដូវវស្សា និងអាចបង្កើតក្លិនកាន់តែអាក្រក់នៅពេលប្រព័ន្ធបង្ហូរទឹកសម្អុយស្ទះ។ បញ្ហាសំរាមនេះទំនងជានឹងត្រូវដោះស្រាយប្រសិនបើការអភិវឌ្ឍកើតមានឡើងនៅក្បែរនោះ។ ឧទាហរណ៍ ប្រសិនបើគេកសាងសណ្ឋាគារថ្មីមួយ វិនិយោគិនទំនងជានឹងដោះស្រាយបញ្ហាសំរាម បើមិនដូច្នេះទេ វាអាចនឹងកាត់បន្ថយតម្លៃគម្រោងនេះ។

## ល្អប្រសើរជាងមុន

កន្លែងសរុបដែលស្ថានភាពសំរាមមានលក្ខណៈល្អប្រសើរឡើងចាប់តាំងពីឆ្នាំ ២០១៤៖ ៧៥ (៥១%)

| តំបន់ | C | O | D | S | តំបន់ | C | O | D | S | | C | O | D | S |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្លូវ ប្រាក់ | ✓ | ✓ | | | ផ្លូវ ៨៧ | ✓ | ✓ | | | ចតុមុខ | ✓ | ✓ | ✓ | |
| ផ្លូវ ១១៨ | ✓ | ✓ | | | ផ្លូវហាយវេ រុស្ស៊ី | ✓ | | | | ផ្លូវ ២៦១ | ✓ | | | |
| ផ្លូវ ៣១៧ | ✓ | ✓ | | | ផ្លូវ ៥៩៨ | ✓ | ✓ | | | ផ្លូវ ២០០២ | ✓ | ✓ | | |
| ផ្លូវ ២០៩ | ✓ | | | | មហាវិថីសម្ដេច សុធារស | ✓ | | | | ផ្លូវ ៨៨ | ✓ | ✓ | | |
| ផ្លូវ ៧០ | ✓ | | ✓ | | ផ្លូវ ៩០៧ | ✓ | ✓ | | | ផ្លូវ ៣៩ | ✓ | | | |
| ផ្លូវ ៣៧០ | ✓ | ✓ | | | ផ្លូវ ៤៥៦ | ✓ | ✓ | | | ផ្លូវ ៤៩ | ✓ | ✓ | ✓ | |
| ផ្លូវ ៥៩០ | ✓ | ✓ | | | ផ្លូវ ១៦០ | ✓ | | | | ផ្លូវ ៩០៧ | ✓ | ✓ | | |
| ផ្លូវ ១៦០ | ✓ | ✓ | | | ផ្លូវ ១៨បេតេ | ✓ | ✓ | | | ផ្លូវហាយវេ ព្រះមុនីវង្ស | ✓ | ✓ | | |
| ផ្លូវ១៣ | ✓ | ✓ | | | ផ្លូវ ១០៥ | ✓ | ✓ | ✓ | | ផ្លូវ ២៦បេតេ | ✓ | ✓ | | ✓ |
| ផ្លូវ ១៩៧ | ✓ | ✓ | | | ផ្លូវ ៣៦៣ | ✓ | ✓ | | | ខណ្ឌដូនពេញ | ✓ | ✓ | | |
| ផ្លូវវេងស្រេង | ✓ | ✓ | ✓ | | ផ្លូវ ២១៤ | ✓ | ✓ | | | ផ្លូវ ៣៦៦ | ✓ | ✓ | | |
| ផ្លូវ ២៧៨ | ✓ | ✓ | | | ផ្លូវ ២១១ | ✓ | ✓ | | | ផ្លូវ ២០អឹមសេ | ✓ | ✓ | | |
| ផ្លូវ ១៨២ | ✓ | ✓ | | | ផ្លូវ ២០០២ | ✓ | ✓ | | | ផ្លូវ ១៥៥ | ✓ | ✓ | | |
| ផ្លូវ ២០៥ | ✓ | | | | ផ្លូវ ៣៧១ | ✓ | ✓ | | | ផ្លូវ ២៨២ | ✓ | ✓ | | |
| ផ្លូវហាយវេ ព្រះមុនីវង្ស | ✓ | ✓ | | | ផ្លូវ ១៣ | ✓ | ✓ | | | ផ្លូវ ៤៣០ | ✓ | ✓ | | |
| ផ្លូវ ១៣ | ✓ | | | | ផ្លូវហាយវេ ព្រះមុនីវង្ស | ✓ | ✓ | | | ផ្លូវ ១៤ | ✓ | ✓ | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្លូវ ៣៣៦ | ✓ | ✓ | | | ផ្លូវ ២៥៧ | ✓ | ✓ | | | ផ្លូវ ៤៣០ | ✓ | ✓ | | |
| ផ្លូវ ៩៣ (ជិតផ្លូវ ៨០) | ✓ | ✓ | | | ផ្លូវ ១០៦ (ផ្សារ) | ✓ | ✓ | | | ផ្លូវ ៩៣ (ខាងកើតផ្លូវមុនីវង្ស) | ✓ | ✓ | | |
| ផ្លូវ ២៧១ (ស្ថានីយប្រព័ន្ធលូទឹកស្អុយ) | ✓ | | | | កែងនឹង ផ្លូវ១០អឹមសេ និង២០អឹមសេ | ✓ | | ✓ | | ផ្លូវ ២១៧ (មណ្ឌលសុខភាព) | ✓ | ✓ | | |
| ផ្លូវវត្តកោះ(មុនីវង្ស) | ✓ | ✓ | | | ផ្លូវវត្តកោះ (ខាងកើត) | ✓ | ✓ | | | ផ្លូវ ២៧១ (ស្ពានអាកាស) | ✓ | ✓ | | |
| កែងនឹង ផ្លូវ ៩៣ និងមុនីវង្ស) | ✓ | ✓ | | | ផ្លូវ ២៣០(នៅជិតផ្លូវ ២៥៧) | ✓ | ✓ | | | ផ្លូវ ១០៦ (ក្បែរទីលានប្រជាធិបតេយ្យ) | ✓ | ✓ | ✓ | |
| ផ្លូវ ២៣០ (សាលាអន្តរជាតិរ៉ូយ៉ាល់) | ✓ | ✓ | | | ផ្លូវ ៣១៧ (ស្ថានីយឧស្ម័ន) | ✓ | ✓ | | | មហាវិថីសម្តេចសុធារស | ✓ | ✓ | | |
| ស្ពានស្ទឹងមានជ័យ | ✓ | ✓ | ✓ | | ផ្លូវ ៣៦៩ (ផ្សារ) | ✓ | ✓ | | | កែងនឹងផ្លូវ ៩៥ ផ្លូវ ១៥៥ & ២៧៨ | ✓ | ✓ | | |
| ផ្លូវ ២៧១(មន្ទីរពេទ្យ) | ✓ | ✓ | | | កែងនឹងផ្លូវ ៥១៣& មុនីរ៉េត | ✓ | ✓ | | | កែងនឹងផ្លូវ ៥៨៥ និងផ្លូវ ១០៥ | ✓ | ✓ | | ✓ |
| កែងនឹងផ្លូវ ១៩៣ និង ៣៣ | ✓ | ✓ | | ✓ | នៅក្បែរសង្កាត់ទឹកថ្លា | ✓ | ✓ | | | សង្កាត់អូរឬស្សី ១ | ✓ | ✓ | | |

| សង្ខេប | តំបន់ | ភាគរយ |
|---|---|---|
| ក្រុមហ៊ុនស៊ិនទ្រីប្រមូល | ៧៥ | ១០០% |
| សំរាមដែលបានរៀបចំរួច | ៦៣ | ៨៤% |
| ជិតតំបន់អភិវឌ្ឍន៍ | ៩ | ១២% |
| ជិតតំបន់ប្រព័ន្ធលូទឹកសម្អុយ | ៣ | ៤% |

## ករណីសិក្សាទី១៖ ផ្លូវ ២៦១

ឆ្នាំ២០១៤



ឆ្នាំ២០១៦



នៅឆ្នាំ២០១៤ សំរាមនៅក្នុងតំបន់នេះគ្មានសណ្ដាប់ធ្នាប់យ៉ាងខ្លាំង ហើយបានបញ្ចេញក្លិនស្អុយខ្លាំង។ គំនរសំរាមធំៗបង្កជាបញ្ហាដល់អ្នកបើកបរឆ្លងកាត់ និងអាជីវកម្មនានាក្នុងមូលដ្ឋាន ហើយប្រជាពលរដ្ឋក្នុងមូលដ្ឋាននឹងប្រឈមការកើតជំងឺដោយសារតែវា។ នៅឆ្នាំ២០១៦នេះ តំបន់នេះបានប្រសើរឡើងច្រើន។ ប្រជាពលដ្ឋម្នាក់នៅក្នុងមូលដ្ឋានដែលជាអ្នកលក់សាច់ និងបន្លែក្បែរនោះបានពន្យល់អ្នកស្រាវជ្រាវសមាគមធាងត្នោតថា គាត់ និងម្ចាស់ផ្ទះផ្សេងទៀតបានដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរមូលដ្ឋានឱ្យជួយទប់ស្កាត់ម្ចាស់ផ្ទះនានាកុំឱ្យបោះចោលសំរាមក្រៅផ្ទះរបស់ពួកគេ (កន្លែងដែលរថយន្តស៊ិនទ្រីចូលទៅមិនដល់)។ នៅពេលប្រជាពលរដ្ឋចាប់ផ្ដើមបោះសំរាមរបស់ពួកគេគរលើកំណាត់ផ្លូវលេខ ២៦១ ម្ចាស់អាជីវកម្មមួយចំនួននៅលើផ្លូវនេះបានប្ដឹងទៅអាជ្ញាធរមូលដ្ឋានម្ដងទៀត ដោយសារតែមានសំរាមច្រើនពេក។ ចាប់តាំងពីពេលនោះមក ក្រុមហ៊ុនស៊ិនទ្រីបានទៅប្រមូលសំរាមជារៀងរាល់ថ្ងៃ ដោយទប់ស្កាត់កុំឱ្យសំរាមគរឡើងច្រើន។ ទោះបីជាសំរាមលែងចោទជាបញ្ហាទៀតនៅក្នុងតំបន់នេះក្ដី ក៏ទឹកកខ្វក់ត្រូវបានបន្សល់ទុកនៅពេលក្រុមហ៊ុនស៊ិនទ្រីប្រមូលសំរាមបង្កជាក្លិនស្អុយ។

## ករណីសិក្សាទី២៖ ផ្លូវ ១០៦ (ជិតទីលានប្រជាធិបតេយ្យ)

ទោះបីជាសំរាមមិនដែលជាចោទបញ្ហាចម្បងនៅក្នុងតំបន់នេះក្ដី ក៏ការបង្កើនការប្រឹងប្រែងប្រមូលសំរាមរាល់ថ្ងៃពីសំណាក់ក្រុមហ៊ុនស៊ិនទ្រីបានធ្វើឱ្យវាប្រសើរឡើងបន្ថែមទៀត។ ទំនងជាដោយសារតំបន់នេះស្ថិតចំកណ្ដាលរាជធានីនៃប្រទេសកម្ពុជា បានធ្វើឱ្យការប្រមូលសំរាម និងថែករក្សាសោភ័ណភាពទូទៅក្លាយជាបញ្ហាអាទិភាព។ លើសពីនេះទៅទៀត វាមានទីតាំងស្ថិតនៅជាប់ស្ថានទូតអាមេរិកជាហេតុជំរុញឱ្យបន្តសម្អាតតំបន់នេះបន្ថែមទៀត។ នៅពេលសមាគមធាងត្នោតបានចុះទៅពិនិត្យតំបន់នេះនៅក្នុងឆ្នាំ២០១៦ ធុងសំរាមរួមត្រូវបានក្រឡាប់ដើម្បីចាក់ទឹកកខ្វក់ចេញ ប៉ុន្តែគ្មានសំរាមសេសសល់នៅជាប់វាទេ អំឡុងពេលគេឈប់ប្រើប្រាស់វា។

## ករណីសិក្សាទី៣៖ ផ្លូវ ៥៩៨

ឆ្នាំ២០១៤



ឆ្នាំ២០១៦



តំបន់សំរាមនេះបានប្រសើរឡើងច្រើនចាប់តាំងពីឆ្នាំ២០១៤មក។ កន្លែងដែលសំរាមគ្មានការរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ ធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងសោភ័ណភាពក្នុងមូលដ្ឋានដែលពីមុនធ្លាប់មានសំរាមរាយប៉ាយតាមបណ្តោយចិញ្ចើមផ្លូវ ពេលនេះកញ្ជេសំរាមស្អាតៗត្រូវបានរៀបចំ ហើយសំរាមត្រូវបានច្រកក្នុងថង់ប្លាស្ទិកដាក់ចូលទៅក្នុងធុងយ៉ាងមានរបៀបរៀបរយ។ ប្រជាពលរដ្ឋមូលដ្ឋានមានការយល់ដឹងជាងមុនអំពីការគ្រប់គ្រងសំរាមតាមរយៈការទំនាក់ទំនងជាមួយមនុស្សផ្សេងទៀត ហើយបានដឹងថាក្រុមហ៊ុនស៊ិនទ្រីនឹងប្រមូលតែសំរាមដែលទុកដាក់បានត្រឹមត្រូវប៉ុណ្ណោះ។ ដោយសារការខិតខំប្រឹងប្រែងទាំងនេះដើម្បីជម្នះបញ្ហាសំរាម ពេលនេះលែងមានក្លិនស្អុយ ឬមានជំងឺដែលគេរាយការណ៍ថាបណ្តាលមកពីសំរាមទៀតហើយ។

## ដូចពីមុន

តំបន់សរុបដែលសំរាមនៅតែដដែលចាប់តាំងពីឆ្នាំ២០១៤ មក៖ ៥៥ (៣៧%)

| ទីតាំង | C | O | D | S | ទីតាំង | C | O | D | S | | C | O | D | S |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្លូវ ១៦៧ | ✓ | | | | ផ្លូវ ១៣២ | ✓ | | | | ផ្លូវសូឡា | ✓ | | | |
| ផ្លូវ ២៣០ | ✓ | ✓ | | | ផ្លូវ ៥៨៦ | ✓ | | | | ផ្សារតេលា | ✓ | | | |
| ផ្លូវ ២៤៩ | ✓ | | | | ផ្លូវ ៤៣០ | ✓ | | | ✓ | កែងនឹងផ្លូវសហព័ន្ធរុស្ស៊ី | ✓ | | | |
| ផ្លូវ ១៣៤ | ✓ | ✓ | | | ផ្លូវ ៥១៦ | ✓ | | | | ផ្លូវហោយតិច | ✓ | | | |
| ផ្លូវ ៣៣៥ | | | | | ផ្លូវ ២០១១ | ✓ | | | | ផ្លូវ ៣១០ | ✓ | | | |
| ផ្លូវ ១៦៧ | | | | | ផ្លូវ ២៨៩ | ✓ | | | | ផ្លូវ ៥២៨ | ✓ | | | |
| ផ្លូវ ៥៣ | ✓ | | | | ផ្លូវ ៣៦៧ | ✓ | ✓ | | | ផ្លូវ ៦០៨ | ✓ | ✓ | | |
| ផ្លូវ ១៨២ | ✓ | ✓ | | | ផ្លូវ ២០១៣ | ✓ | | | | ផ្លូវ ១៣៨ | ✓ | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្លូវ ២០០៤ | ✓ | | | | ផ្លូវ ១២៨ | ✓ | | | | ផ្លូវ ២៩១ | ✓ | | | |
| ផ្លូវ ១០២ | ✓ | ✓ | | | ផ្លូវ ១០៨ | ✓ | ✓ | | | ផ្លូវវេងស្រេង | ✓ | ✓ | | |
| ផ្លូវ ៣១០ | ✓ | | | | ផ្លូវ ១៧៣ | ✓ | | | ✓ | ផ្លូវ ១០១៩ | ✓ | | | |
| ផ្លូវ ២៣០ | ✓ | | | | ផ្លូវ ២០០៧ | ✓ | ✓ | | | ផ្លូវ ១៨៧ | ✓ | | | |
| ផ្លូវកែវ ចិន្តា | ✓ | | | | ផ្លូវ ៨៥៦ | ✓ | | | | ផ្លូវ ៣៨៤ | ✓ | | | ✓ |
| ផ្លូវ ២៧១ | ✓ | | | | ផ្លូវ កា៥ | ✓ | | | | ផ្លូវ ១០៦ | | | | |
| ផ្លូវ ២១៧ (ភោជនីយដ្ឋាន) | ✓ | | | | ផ្លូវ អឹមសេ (ជិតផ្លូវ ៧អឹមសេ) | ✓ | | | | សហាគមន៍ អេស អូ អេស (SOS) | ✓ | | | |
| កែងនឹងផ្លូវ ១៩៩ និង២៨៤ | | | | | ផ្លូវ ២៣០ (បឹងសាឡាង) | ✓ | | | ✓ | ផ្លូវ ២៣០ (ផ្សារ) | ✓ | | | ✓ |
| កែងនឹងផ្លូវ ៦០៨ និង១៣២ | | | | | កែងនឹងផ្លូវ ១០៥ និង៨៣២ | ✓ | | | | ភូមិត្រពាំងថ្លឹង | ✓ | ✓ | | ✓ |
| កែងនឹងផ្លូវ ៣៦៦ និង១៧៣ | ✓ | | | ✓ | កែងនឹងផ្លូវ ១០អឹមសេ និង៧៣បេតេ | | | | | កែងនឹងផ្លូវ ២៣០ និង២៥៧ | ✓ | | | |
| ផ្លូវវត្តកោះ (ខាងជើង) | ✓ | | | | | | | | | | | | | |

| **សង្ខេប** | តំបន់ | ភាគរយ |
|---|---|---|
| ក្រុមហ៊ុនស៊ិនទ្រីទៅប្រមូលសំរាម | ៤៩ | ៨៩% |
| សំរាមដែលត្រូវបានរៀបចំទុកដាក់ត្រឹមត្រូវ | ១០ | ១៨% |
| ជិតតំបន់អភិវឌ្ឍន៍ | 0 | 0% |
| ជិតប្រព័ន្ធលូ | ៧ | ១៣% |

## ករណីសិក្សាទី៤៖ ផ្លូវ ៣៣៥

ឆ្នាំ២០១៤ ឆ្នាំ២០១៦







នៅឆ្នាំ២១៤ មានសំរាមដែលគ្មានការទុកដាក់ឱ្យបានត្រឹមត្រូវជាច្រើនគរនៅលើចិញ្ចើមផ្លូវ។ កត្តានេះបានបញ្ចេញក្លិនស្អុយ និងធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ជាពិសេស កុមារមានសុខភាពមិនល្អដោយសារតែគំនរសំរាម ពីព្រោះតំបន់នេះស្ថិតនៅទល់មុខសាលារៀនមួយដែលមានថ្នាក់មត្តេយ្យ និងថ្នាក់បឋមសិក្សា។ បន្ទាប់ពីចុះទៅតំបន់នេះម្តងទៀតនៅក្នុងឆ្នាំ២០១៦ សមាគមធាងត្នោតបានសង្កេតឃើញថា តំបន់នេះមិនបានប្រសើរឡើងទេ ដោយសំរាមមួយចំនួនដែលគ្មានការរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវនៅតែមានលើចិញ្ចើមផ្លូវ។ ទោះជាយ៉ាងណា តំបន់នេះលែងក្លាយជាកន្លែងចាក់សំរាមទៀតហើយ ហើយប្រជាពលរដ្ឋក្នុងតំបន់ជុំវិញនេះបានចាប់ផ្តើមគ្រប់គ្រងសំរាមរបស់ខ្លួនដើម្បីទប់ស្កាត់កុំឱ្យសហាគមន៍នេះកាន់តែអាក្រក់មើល។ ពេលនេះ សំរាមត្រូវបានរៀបចំមានរបៀបរៀបរយ និងដាក់នៅខាងក្រៅលំនៅដ្ឋានប្រជាពលរដ្ឋនីមួយៗ ជាកន្លែងដែលក្រុមហ៊ុនស៊ិនទ្រីទៅប្រមូលជារៀងរាល់ថ្ងៃ។ បន្ថែមពីលើប្រជាពលរដ្ឋរៀបចំទុកដាក់សំរាមរបស់ពួកគេនៅក្នុងធុង ហើយសាលារៀនក្នុងមូលដ្ឋានបានចាប់ផ្តើមរៀបចំទុកដាក់សំរាមរបស់ខ្លួនក្នុងធុងជ័រ កន្លែងដែលក្រុមហ៊ុនស៊ិនទ្រីទៅប្រមូលយកជារៀងរាល់ថ្ងៃផងដែរ។ ដោយសារសំរាមមិនត្រូវបានបោះចោល (ដោយគ្មានរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ) នៅកន្លែងនេះទៀត តំបន់ជុំវិញនោះពិតជាមើលទៅស្អាតជាងមុន។ ទោះជាយ៉ាងណា នៅតែត្រូវខិតខំប្រឹងប្រែងដើម្បីសម្អាតតំបន់នេះ ដែលក្រុមហ៊ុនស៊ិនទ្រីមិនទៅប្រមូលសំរាមដោយសារតែសំរាមមិនត្រូវបានរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ។

ករណីសិក្សាទី៥៖ ផ្លូវ ២០០៧

ឆ្នាំ២០១៤ ឆ្នាំ២០១៦





នៅឆ្នាំ២០១៤ សំរាមដែលគ្មានការរៀបចំទុកដាក់ត្រឹមត្រូវ ត្រូវគេបោះចោលនៅលើផ្លូវលេខ២០០៧ ធ្វើឱ្យប៉ះពាល់ដល់ចរាចរណ៍ឆ្លងកាត់ បញ្ចេញក្លិនស្អុយ និងរំខានដល់អាជីវកម្ម ទីធ្លាលេងកម្សាន្ត និងកន្លែងជួបជុំគ្នា។ បើទោះបីជានៅក្នុងឆ្នាំ២០១៦ ក្រុមហ៊ុនស៊ិនទ្រីមកប្រមូលសំរាមរាល់ល្ងាច (នៅម៉ោង ៨:០០ ឬ ៩:០០យប់) ក្តី ក៏ប្រជាពលរដ្ឋមួយចំនួន និងអាជីវកម្មក្បែរៗនោះនៅតែយកសំរាមរបស់ពួកគេចេញមកឃឹត ជាហេតុធ្វើឱ្យសំរាមគរជាប្រចាំ។ ទោះជាយ៉ាងណា ទិដ្ឋភាពមួយចំនួនមានភាពប្រសើរឡើង ដោយភោជនីយដ្ឋានមួយក្នុងមូលដ្ឋានដែលបានចំណាយប្រាក់ស្ថាបនាផ្លូវនេះឡើងវិញ បានព្យាយាមជំរុញឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានរៀបចំសំរាមរបស់ពួកគេ និងរក្សាទុកវាឱ្យមានរបៀបរៀបរយជាងមុន។ ទោះបីជាពេលនេះសំរាមមួយចំនួនត្រូវបានរៀបចំបានត្រឹមត្រូវក្តី ក៏ការគ្មានធុងគ្រប់គ្រាន់សម្រាប់ដាក់សំរាម ហើយហាក់នៅតែចោទជាបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរណ៍ និងសុខភាពរបស់ប្រជាជនក្នុងតំបន់នេះ។

## កាន់តែអាក្រក់ជាងមុន

តំបន់សរុបដែលស្ថានភាពសំរាមកាន់តែអាក្រក់ជាងមុនចាប់តាំងពីឆ្នាំ២០១៤ មក៖ ១៧ (១២%)

| ទីតាំង | C | O | D | S | ទីតាំង | C | O | D | S | | C | O | D | S |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្លូវ ៣៥០ | ✓ | | | | ផ្លូវ ២៣៤ | ✓ | | | | ផ្លូវ ២០៣ | ✓ | | | |
| ផ្លូវ ៥ | ✓ | ✓ | | | ផ្លូវ ២៦៥ | ✓ | | | | ផ្សារចាស់ | ✓ | | | ✓ |
| ផ្លូវ ១២៣ | | | | | ផ្លូវរថភ្លើង | ✓ | | | | ផ្លូវ ១៨៧ | ✓ | | | |
| ផ្លូវដូងងៀប | ✓ | | | ✓ | ផ្លូវ ៦១០ | ✓ | | | | ផ្លូវ ៨៦កា | ✓ | | | |
| ផ្លូវបេតុង ២១០៥ | ✓ | | | | ផ្លូវ ៩០៧ | ✓ | | | | ផ្លូវ ២១៧ (កែងនឹងស្ថានអាកាស) | ✓ | | | |
| ក្តីសង្ឃឹម (វិហារ) | ✓ | | | | ជិតភូមិទ្រា | | | | | | | | | |

| សង្ខេប | តំបន់ | ភាគរយ |
|---|---|---|
| ក្រុមហ៊ុនស៊ិនទ្រីទៅប្រមូលសំរាម | ១៥ | ៨៨% |
| សំរាមដែលត្រូវបានរៀបចំទុកដាក់ត្រឹមត្រូវ | ១ | ៦% |
| ជិតតំបន់អភិវឌ្ឍន៍ | ០ | ០% |
| ជិតប្រព័ន្ធលូ | ២ | ១២% |

## ករណីសិក្សាទី៦៖ ផ្លូវ ២៦៥

ឆ្នាំ២០១៤ ឆ្នាំ២០១៦







ការរៀបរាប់របស់សំឡេងទីក្រុង (Urban Voice) អំពីផ្លូវលេខ២៦៥ បានបង្ហាញពីគំនរសំរាមស្អុយរលួយដែលបំពុលបរិស្ថានតំបន់មូលដ្ឋាន និងបង្កឱ្យមានបញ្ហាសុខភាពផ្លូវដង្ហើម។ នៅឆ្នាំ២០១៦ សមាគមធាងត្នោតបានសង្កេតឃើញថា ស្លាកសញ្ញាបម្រាមមួយត្រូវបានលើក ក្នុងគោលបំណងទប់ស្កាត់ការចាក់សំរាមដែលគ្មានការរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវនៅលើចិញ្ចើមផ្លូវ។ ទោះបីជាប្រជាពលរដ្ឋមួយចំនួនក្នុងមូលដ្ឋានយល់ថា ក្រុមហ៊ុនស៊ិនទ្រីនឹងមកប្រមូលសំរាម ប្រសិនបើវារៀបចំទុកដាក់បានត្រឹមត្រូវ (ដូចជាសំរាមច្រកក្នុងថង់ប្លាស្ទិកជាដើម) ក្តី ក៏ប្រជាពលរដ្ឋជាច្រើនដែលមានទម្លាប់មិនល្អបានបន្តចាក់សំរាមដែលគ្មានការទុកដាក់បានត្រឹមត្រូវនៅទីនេះ។ ទោះបីជាក្រុមហ៊ុនស៊ិនទ្រីមកប្រមូលសំរាមជារៀងរាល់ថ្ងៃក្តី ក៏ទឹកកខ្វក់បន្សល់ពីសំរាមដែលគ្មានការរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវនៅតែមានលើចិញ្ចើមផ្លូវរយៈពេលយូរ ជាហេតុធ្វើឱ្យតំបន់នេះកាន់តែអាក្រក់ជាងមុនទៅទៀត។ ស្ត្រីអ្នករកស៊ីម្នាក់នៅក្នុងមូលដ្ឋានបានពន្យល់ពីភាពបន្ទាន់ដែលត្រូវដោះស្រាយបញ្ហានេះឱ្យបាន ពីព្រោះសំរាមស្ថិតនៅពីក្រោយមន្ទីរពេទ្យព្រះកុសុមៈ ហើយវាអាចបង្កជំងឺបន្ថែមទៀតដល់អ្នកដែលមានជំងឺដែលឈឺរួចទៅហើយ។ ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលនៅក្បែរនោះបានហៅទូរស័ព្ទចូលវិទ្យុ អេ ប៊ី ស៊ី (ABC) ដើម្បីលើកឡើងពីការព្រួយបារម្ភរបស់ពួកគេ ប៉ុន្តែសំរាមនៅតែចោទជាបញ្ហាដដែល។

## សេចក្ដីសន្និដ្ឋាន

មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ទាក់ទងនឹងសំរាមក្នុងរាជធានីភ្នំពេញ។ តួលេខបង្ហាញថា ៥១% នៃទីតាំងទាំងអស់ មានភាពប្រសើរឡើងចាប់តាំងពីឆ្នាំ២០១៤មក។ ភាពខុសគ្នាមួយដែលគួរឱ្យកត់សម្គាល់រវាងតំបន់ដែលមានភាពប្រសើរឡើង និងតំបន់ដែលមានស្ថានភាពដដែល ឬកាន់តែអាក្រក់ គឺចំនួនតំបន់ដែលរៀបចំទុកដាក់សំរាមរបស់ពួកគេ (៨៤% ប្រសើរឡើង ១៨% នៅដដែល ៦% កាន់តែអាក្រក់)។ ភាគច្រើននៃតំបន់ទាំងនេះមានភាពប្រសើរឡើងចាប់តាំងពីឆ្នាំ ២០១៤ មក ដោយសារពេលនេះសំរាមត្រូវបានរៀបចំទុកដាក់បានត្រឹមត្រូវ ដូច្នេះហើយក្រុមហ៊ុនស៊ិនទ្រីក៏ទៅប្រមូលវា។ លើសពីនេះទៀត មានការកត់សម្គាល់ថា អំឡុងពេលប្រមូលទិន្នន័យ ជាមធ្យម តំបន់ "ល្អប្រសើរ" ត្រូវក្រុមហ៊ុនស៊ិនទ្រីទៅប្រមូលសំរាមជារៀងរាល់ថ្ងៃ ចំណែកឯតំបន់ "នៅដដែល" ក្រុមហ៊ុនស៊ិនទ្រីទៅប្រមូល៣ ទៅ ៤ ថ្ងៃក្នុងមួយសប្ដាហ៍ ហើយតំបន់ "កាន់តែអាក្រក់ជាងមុន" ក្រុមហ៊ុនទៅប្រមូលតែម្ដងប៉ុណ្ណោះក្នុងមួយសប្ដាហ៍។ នេះប្រហែលដោយសារតែសំរាមដែលរៀបចំទុកដាក់បានត្រឹមត្រូវ (ឧទាហរណ៍ តំបន់ដែលកាន់តែអាក្រក់ទៅចាប់តាំងពីឆ្នាំ២០១៤មក មានតែតំបន់ ១ ប៉ុណ្ណោះដែលបានរៀបចំសំរាមបានត្រឹមត្រូវ) ប៉ុន្តែវាក៏ប្រហែលជាដោយសារថា ក្រុមតំបន់ "នៅដដែល" និងតំបន់ "កាន់តែអាក្រក់ជាងមុន" ស្ថិតក្នុងទីតាំងដែលក្រុមហ៊ុនស៊ិនទ្រីមិនអាចទៅដល់ផងដែរ (ឧទាហរណ៍ ផ្លូវចង្អៀត) ឬពួកគេមិនផ្ដល់សេវាក្នុងតំបន់នោះតែម្ដង។

កត្តាមួយទៀតដែលធ្វើឱ្យប្រសើរឡើងទំនងជាមកពីការអភិវឌ្ឍក្បែរនោះ។ កន្លែងដែលមានការអភិវឌ្ឍថ្មីកំពុងកើតឡើង (ឬបានបញ្ចប់រួចរាល់) នៅក្បែរតំបន់សំរាម បញ្ហាសំរាមត្រូវបានដោះស្រាយ។ នេះទំនងជាដោយសារការចង់ឱ្យបរិស្ថានមានសោភ័ណភាពដោយជំរុញឱ្យវិនិយោគិន ឬអ្នកបញ្ជាទិញយកចិត្តទុកដាក់បន្ថែមទៀតចំពោះតំបន់ជុំវិញរបស់ខ្លួន។

ផ្លូវលេខ២៧៨ (ប្រសើរឡើង)



ប្រភព៖ សមាគមធាងត្នោត ឆ្នាំ២០១៦

ផ្លូវលេខ១៦៧ (នៅដដែល)



ប្រភព៖ សមាគមធាងត្នោត ឆ្នាំ២០១៦

ផ្លូវលេខ១២៣ (កាន់តែអាក្រក់ជាងមុន)



ប្រភព៖ សមាគមធាងត្នោត ឆ្នាំ២០១៦

**អនុសាសន៍**

ការស្រាវជ្រាវនេះបង្ហាញថា ដោយសារសំរាមត្រូវបានរៀបចំទុកដាក់បានត្រឹមត្រូវ តំបន់នេះស្អាតជាងមុន។ ដូច្នេះ អនុសាសន៍សំខាន់គឺត្រូវជំរុញឱ្យប្រជាពលរដ្ឋ និងអាជីវកម្មនានាក្នុងមូលដ្ឋានឱ្យរៀបចំសំរាមរបស់ពួកគេក្នុងថង់ប្លាស្ទិក ឬធុងសំរាមរួម (ប្រសិនបើមាន) ដើម្បីឱ្យក្រុមហ៊ុនស៊ិនទ្រីមកប្រមូល។ នៅតំបន់ខ្លះ មានការយល់ដឹងច្រើនអំពីការគ្រប់គ្រងសំរាម (ឧទាហរណ៍ ផ្លូវលេខ៥៩៨) ទោះជាយ៉ាងណា ប្រជាពលរដ្ឋជាច្រើន និងអាជីវកម្មនានាក្នុងមូលដ្ឋានដែលនៅខ្វះការយល់ដឹង ឬមានទម្លាប់មិនល្អ បន្តចាក់សំរាមពាសវាលពាសកាល និងមិនរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ។ ដោយសារកត្តានេះ ហើយអាជ្ញាធរមូលដ្ឋានគួរតែបង្កើនការយល់ដឹងអំពីការគ្រប់គ្រងសំរាមនៅក្នុងតំបន់របស់ខ្លួន។

ខណៈមានការខិតខំប្រឹងប្រែងនេះ ប្រជាពលរដ្ឋ និងអាជីវកម្មនានាក្នុងមូលដ្ឋានអាចធ្វើបានតំបន់មួយចំនួននឹងបន្តមានបញ្ហាសំរាម ប្រសិនបើក្រុមហ៊ុនស៊ិនទ្រីមិនទៅប្រមូលសំរាមឱ្យបានទៀងទាត់។ អាជ្ញាធររដ្ឋាភិបាលត្រូវធានាថា ក្រុមហ៊ុនស៊ិនទ្រីអាចផ្តល់សេវាគ្រប់គ្រាន់ ជាពិសេសកិច្ចសន្យារបស់ពួកគេដែលត្រូវបន្តនៅខែឧសភា ឆ្នាំ២០១៦ ហើយដោយសារចំនួនប្រជាជនក្នុងរាជធានីភ្នំពេញ ចេះតែបន្តកើនឡើង វានឹងធ្វើឱ្យស្ថានភាពសំរាមក្នុងរាជធានីកាន់តែអាក្រក់ទៅ ប្រសិនបើក្រុមហ៊ុនស៊ិនទ្រីមិនអាចផ្តល់សេវាគ្រប់គ្រាន់ទេនោះ។ ប្រសិនបើក្រុមហ៊ុនស៊ិនទ្រីមិនផ្តល់សេវាប្រមូលសំរាមឱ្យបានល្អនោះទេ ប្រជាពលរដ្ឋ និងអាជីវកម្មនានាក្នុងមូលដ្ឋានគួរតែត្រូវបានលើកទឹកចិត្តឱ្យទាក់ទងទៅអាជ្ញាធរមូលដ្ឋាន ហើយទាមទារសេវាដែលល្អប្រសើរជាងនេះ។